សហគមន៍ខ្មែររដ្ឋញូវសោធវែល

KHMER COMMUNITY OF NSW Inc.

Registration No: Y01459-42 26 Bonnyrigg Avenue, Bonnyrigg NSW 2177

# សេចក្តីជូនដំណឹងអំពីកិច្ចប្រជុំពិសេសនៃការបោះឆ្នោតប្រធានសហគមន៍ថ្មីឆ្នាំ ២០២៤ - ២០២៦

**កាលបរិច្ឆេទ:** ថ្ងៃអាទិត្យ, 22 ធ្នូ 2024
**ពេលវេលា:** 1:00 រសៀលដល់ 3:00 រសៀល
**ទីកន្លែង:** សហគមន៍ខ្មែររដ្ឋ NSW,
26 Bonnyrigg Ave, Bonnyrigg NSW 2177

**សមាជិកសហគមន៍ទាំងអស់ជាទីគោរព,**

សូមគោរពជូនដំណឹងដល់សមាជិកសហគមន៍ទាំងអស់អោយបានជ្រាបថា កិច្ចប្រជុំពិសេសសម្រាប់ការបោះឆ្នោតជ្រើសរើសប្រធានសហគមន៍ថ្មីនឹងប្រព្រឹត្តទៅនៅម៉ោង 1:00 រសៀល ថ្ងៃអាទិត្យ ទី 22 ខែធ្នូ ឆ្នាំ 2024 នៅវត្តខ្មែរ បូន្នីរីគ 26 Bonnyrigg Avenue, Bonnyrigg, NSW 2177 ។ ការបោះឆ្នោតជ្រើសរើសប្រធានសហគមន៍ខ្មែរ ដែលតែងតែធ្វើឡើងរៀងរាល់ពីរឆ្នាំម្តង នឹងប្រព្រឹត្តទៅចាប់ពីម៉ោង 1:00 ដល់ម៉ោង 3:00 រសៀលនៅក្នុងសាលក្រោមព្រះវិហារវត្តបូន្នីរីគ ។

សេចក្តីជូនតំណឹងនេះចាត់ទុកជាសេចក្តីអញ្ជើញដល់សមាជិករបស់សហគមន៍ទាំងអស់ដើម្បីមកចូលរួមធ្វើការបោះឆ្នោតជ្រើសរើសប្រធានសហគមន៍ថ្មីម្នាក់ដែលអាចមានលទ្ធភាពដឹកនាំសហគមន៍របស់យើងបន្តទៅមុខទៀត ។

**ការតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោត៖**

សមាជិកទាំងឡាយណាដែលមានបំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោត ត្រូវមកបំពេញទម្រង់បែបបទតែងតាំងអោយបានមុនឬត្រឹមថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2024 ភ្ជាប់មកជាមួយនូវ National Police Check ពី AFP (តម្លៃប្រហែល 99 ដុល្លារ)។ ទម្រង់ពាក្យសុំ National Police Check Online អាចរកបាននៅ AFP National Police Checks ។

ទម្រង់បែបបទតែងតាំងដែលបានបំពេញរួចហើយអាចដាក់នៅក្នុងស្រោមសំបុត្របិទជិត ផ្ញើរមកអោយអ្នករៀបចំការបោះឆ្នោត c/- 26 Bonnyrigg Avenue, Bonnyrigg 2177 ។ តម្រូវការនេះត្រូវបានចែងនៅក្នុងលេខទី 12 នៃរដ្ឋធម្មនុញ្ញនៃសហគមន៍ខ្មែររដ្ឋញូវសោជវែល ។ ច្បាប់ចម្លងនៃទម្រង់បែបបទតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោតមាននៅការិយាល័យសហគមន៍ខ្មែរ ។

ការចុះឈ្មោះសមាជិកភាពសម្រាប់ការបោះឆ្នោតនឹងត្រូវបិតនៅថ្ងៃទី 15 ខែធ្នូ ឆ្នាំ 2024 វេលាម៉ោង 5:00 ល្ងាច ។ ក្រោយពីកាលបរិច្ឆេទខាងលើ សមាជិកនៅអាចនៅបន្តចូលរួមចុះឈ្មោះបាន ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតក្នុងពេលបោះឆ្នោតនេះទេ ។

សម្រាប់សំនួរបន្ថែម សូមទាក់ទងសហគមន៍ខ្មែរតាមរយៈលេខ 02 9823 3479 ឬទាក់ទងប្រធានសហគមន៍ខ្មែរ លោកស្រី Chanthy Lim-chum តាមរយៈលេខ 0426 188 396 ឬអ៊ីម៉ែល៖ info@khmer.org.au។

ដោយក្តីគោរព

Chanthy Lim-chum ប្រធានសហគមន៍ខ្មែររដ្ឋ NSW Inc.
30 វិច្ឆិកាវិច្ឆិកា 2024